KRESTON CAMBODIA

# របាយការណ៍របស់សវនករឯករាជ្យ

# ស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក

# របាយការណ៍ហិរញ្ញវត្ថុ

# សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022


All rights reserved @ 2023

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1-3 |
| របាយការណ៍របស់សវនករឯករាជ្យ | 4-7 |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន | 8 |
| របាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ | 9 |
| របាយការណ៍បម្រែបម្រួលមូលធន | 10 |
| របាយការណ៍លំហូរសាច់ប្រាក់ | 11 |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 12-38 |

ស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក

C.K.L.S Finance Plc.

1

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមភ្ជាប់នូវរបាយការណ៍នេះ ជាមួយរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរបស់ ស៊ី.ខេ. អិល. អេស ហ្វាយនែន ម.ក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022។

## ១. ព័ត៌មានអំពីក្រុមហ៊ុន

ស៊ី.ខេ. អិល. អេស ហ្វាយនែន ម.ក ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម (“MOC”) ក្រោមលេខចុះបញ្ជី No. 2000100564 ចុះថ្ងៃទី 03 ខែ ធ្នូ ឆ្នាំ 2021។ នៅថ្ងៃទី 27 ខែ កញ្ញា ឆ្នាំ 2021 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (“NBC”) ដើម្បីធ្វើប្រតិបត្តិការជាប្រតិបត្តិករឥណទានជនបទក្នុងប្រទេសកម្ពុជា ក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ផ្តោតសំខាន់ក្នុងការធ្វើសកម្មភាពអាជីវកម្មផ្តល់ឥណទានខ្នាតតូច និងការផ្តល់សេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅ#204 ផ្លូវ 19 ភូមិស្ទួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ។

## ២. លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 និងកិច្ចការរបស់ក្រុមហ៊ុនដល់កាលបរិច្ឆេទនេះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ពុំមានការស្នើសុំបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022។

## ៣. ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងកំឡុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម÷

| **ឈ្មោះ** | **មុខតំណែង** |
|---|---|
| លោក ស្វាយ សុខខេន | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក ពិចិត្រ បុត្រា | អភិបាល |
| លោក ផេង ភាព | អភិបាល |
| លោក យ៉ាន សួរឿន | អភិបាល |
| លោក យូ សៅសំភា | អភិបាល |
| លោក យ៉ាន ពេញ | អភិបាល |
| លោក នួច ថារ៉ូ | អភិបាល |

## ៤. សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 បានធ្វើសវនកម្មដោយ Kreston Cambodia ប្រតិបត្តិការអាជីវកម្មក្រោមឈ្មោះក្រុមហ៊ុន ខេម អ៊ីខោនធីង & ថាកស៊ើវីស ឯ.ក (Cam Accounting & Tax Service Co., Ltd.)។

## ៥. ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុដែលរៀបចំឡើងបានបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវនូវស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់នេះ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលក៏តម្រូវឱ្យ÷

(ក) អនុវត្តគោលនយោបាយគណនេយ្យ ដែលអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

(ខ) គោរពតាមការលាតត្រដាងនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនជាមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់យោបល់លើចំនុចមិនត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) ថែរក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែករណីមិនសមស្របណាដែលថាក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព ចូលរួមលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ដូច្នេះ ត្រូវប្រាកដថាសេចក្តីសម្រេចទាំងនោះត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ៦. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អភិបាលបានទទួលខុសត្រូវ យកចិត្តទុកដាក់ទៅលើចំនុចដូចខាងក្រោម÷

(ក) រាល់សារវន្តទាំងអស់ផ្ទេរទៅ ឬមកពីទុនបម្រុង ឬសំវិធានធនក្នុងឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(ខ) បង្គរកំហាត់បង់ឱនភាពនៃតម្លៃលើឥណទានផ្តល់ដល់អតិថិជន និងទ្រព្យសកម្មបច្ចុប្បន្ន និងទ្រព្យអកម្មឱ្យបានគ្រប់គ្រាន់បើចាំបាច់ត្រូវបានធ្វើឡើង

(គ) បំណុលអសារបង់ ត្រូវបានលុបចោល ប្រសិនបើមាន

(ឃ)វិធីសាស្ត្រនៃការវាយតម្លៃទ្រព្យសកម្ម ឬបំណុលដែលមានស្រាប់គឺមិនបំភាន់ ឬមិនសមរម្យ

(ង) មិនមានកាលៈទេសៈណាមួយ នាំអោយមានការបំភាន់ ចំនួនទឹកប្រាក់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ

(ច) ក្នុងចន្លោះពេលរវាងរបាយការណ៍ហិរញ្ញវត្ថុចុងឆ្នាំ និងកាលបរិច្ឆេទនៃរបាយការណ៍ នេះមិនមានប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយជាសារវន្ត និងប្រតិបត្តិការមិនប្រក្រតីដែលតាមទស្សនៈរបស់អភិបាលធ្វើឱ្យប៉ះពាល់ ដល់លទ្ធផលនៃប្រតិបត្តិការរបស់ស្ថាប័ន សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ

(ឆ) មិនមានប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយជាសារវន្ត និងប្រតិបត្តិការមិនប្រក្រតី ដែលតាមទស្សនៈ របស់អភិបាលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ស្ថាប័ន ក្នុងឆ្នាំហិរញ្ញវត្ថុនេះឡើយ

(ជ) គ្មានយថាហេតុ ឬបំណុលផ្សេងទៀតរបស់ស្ថាប័នអាចកើតមានកាតព្វកិច្ច ឬអាចនឹងត្រូវបានអនុវត្តក្នុង រយៈពេល 12 ខែ បន្ទាប់ពីឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់របស់ស្ថាប័ន នៅពេលដែលដល់កាលវេលាកំណត់។

## ៧. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងនាមក្រុមប្រឹក្សាភិបាលនៃស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក ខ្ញុំសូមបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់ មកជាមួយ ត្រូវបានបង្ហាញពីទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 របាយការណ៍លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) និងគោល ការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

តំណាងក្រុមប្រឹក្សាភិបាល

**លោក ផេង ភាព**

**នាយកប្រតិបត្តិ**

ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

27 មិថុនា 2023

Kreston Cambodia is trading under name of
Cam Accounting & Tax Service Co., Ltd.
Certified Public Accountants and Auditors
Tax Agent License (GDT Member)
Audit Firm License (KICPAA Member)
Financial Institution Audit License (NBC Member)

Address: #3D, Street 416, Sangkat Tumnup Tuek, Khan Beong Keng Kong, Phnom Penh, Cambodia
Tel: (855) 93 33 51 58
(855) 12 75 32 57
E-mail: info@krestoncambodia.com
www.krestoncambodia.com

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិករបស់ ស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក

### មតិយោបល់លើកលែង

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ព្រមទាំងរបាយការណ៍ចំណេញ ខាត និងចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ដូចមានបង្ហាញក្នុងទំព័រលេខ 8 ដល់លេខ 38។

តាមមតិយោបល់របស់យើងខ្ញុំ លើកលែងតែបញ្ហាដែលបានពិពណ៌នាក្នុងមូលដ្ឋាននៃការបញ្ចេញមតិ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុនិង លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ បញ្ចប់ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs ) រួមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា (“NBC”)។

### មូលដ្ឋាននៃការបញ្ចេញមតិលើកលែង

យើងមិនយល់ស្របទៅនឹងប្រាក់ចំណេញរក្សាទុក នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 ក្នុងទឹកប្រាក់ចំនួន 543,240 ពាន់រៀល និងសមតុល្យដើមគ្រានោះទេ ដោយសារតែយើងមិនទទួលបានភស្តុតាងគ្រប់គ្រាន់។ ជាលទ្ធផលនៃបញ្ហាទាំងនេះ យើងមិនអាចកំណត់ថាតើមានការកែតម្រូវណាមួយអាចត្រូវបានរកឃើញទាក់ទងនឹង ប្រាក់ចំណេញរក្សាទុកដែលបានកត់ត្រា ឬមិនបានកត់ត្រា និងធាតុផ្សំផ្សេងៗនៃរបាយការណ៍ចំណេញ ខាត និងចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ លំហូរសាច់ប្រាក់។

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសនវកម្មអន្តរជាតិនៃកម្ពុជា (“ ស. ស. អ. ក”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដាទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្នុងរបាយការណ៍នេះ។ យើងជឿថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ឯករាជ្យភាព និងទំនួលខុសត្រូវសីលធម៌ផ្សេងៗ

យើងមានភាពឯករាជ្យពីក្រុមហ៊ុន ដោយអនុលោមតាមតម្រូវការសីលធម៌ដែលពាក់ព័ន្ធទៅនឹងសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុរបស់យើងនៅក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញនូវទំនួលខុសត្រូវប្រកបដោយក្រមសីលធម៌ផ្សេងទៀតរបស់យើងស្របតាមតម្រូវការទាំងនេះ។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

អភិបាលរបស់ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវរាល់ព័ត៌មានដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ព័ត៌មាននោះរួមបញ្ចូលទាំងរបាយការណ៍ក្រុមអភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបញ្ចេញមតិលើរបាយការណ៍នេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ទំនួលខុសត្រូវរបស់សវនករ គឺគ្រាន់តែអានពីរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងពិចារណាថាតើ របាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនស៊ីសង្វាក់គ្នាខ្លាំងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឬក៏ការយល់ដឹងរបស់យើងដែលទទួលបានក្នុងកំឡុងពេលធ្វើ សវនកម្មទំនងជាបង្ហាញពីកំហុសជាសារវន្ត។

ប្រសិនបើយោងទៅតាមការងារដែលពួកយើងបានបំពេញ រួចសន្និដ្ឋានថា របាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានកំហុសជាជាសារវន្ត ដែលតម្រូវអោយយើងរាយការណ៍ពីការពិតនេះ។ យើងគ្មានអ្វីដែលត្រូវរាយការណ៍ពីបញ្ហានេះឡើយ។

## ទំនួលខុសត្រូវរបស់អភិបាលនៅលើរបាយការណ៍ហិរញ្ញវត្ថុ

អភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ អភិបាលរបស់ក្រុមហ៊ុនទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអភិបាលក្រុមហ៊ុនយល់ថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អភិបាលមានទំនួលខុសត្រូវលើការវាយតម្លៃ និរន្តភាពរបស់ក្រុមហ៊ុនលាតត្រដាងរាល់បញ្ហាដែលមានជាប់ពាក់ព័ន្ធជាមួយនិងនិរន្តភាពរបស់ក្រុមហ៊ុននិងការប្រើប្រាស់មូលដ្ឋាននិរន្តភាពលើកលែងតែអភិបាលមានបំណងចង់បិទក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសពិតប្រាកដក្រៅពីធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងគឺ ដើម្បីទទួលបាននូវការធានាសមហេតុផលអំពីរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូលមិនមានកំហុសឆ្គងជាសារវន្តមិនថាដោយសារការក្លែងបន្លំឬការភាន់ច្រឡំ និងការចេញរបាយការណ៍សវនករដែលរាប់បញ្ចូលទាំងទស្សនៈរបស់យើង។ ការធានាសមហេតុផលគឺជាកម្រិតខ្ពស់នៃការធានា ប៉ុន្តែមិនធានាថាសវនកម្ម

ដែលធ្វើឡើងស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា នឹងរកឃើញកំហុសជាសារវន្តនៅពេលកើតឡើងនោះទេ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសហើយត្រូវបានគេចាត់ទុកថាជាសារវន្ត ក្នុងមួយឬច្រើនករណីបូកបញ្ចូលគ្នា ដែលករណីទាំងនេះអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដែលផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។ផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈនិងរក្សានូវជំនាញវិជ្ជាជីវៈក្នុងការធ្វើសវនកម្មទាំងមូល។ យើងក៏÷

(ក) កំណត់និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន មិនថាដោយសារការក្លែងបន្លំឬកំហុស រៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបានភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់នឹងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ទស្សនៈរបស់យើង។ ហានិភ័យដែលមិនរកឃើញកំហុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងកំហុសដែលបណ្តាលមកពីភាពកំហុស ការការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ ការលុបចោលដោយចេតនាការ ការលាតត្រដាងមិនពិត ឬការរំលោភប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង

(ខ) ទទួលបានការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសវនកម្មដើម្បីរៀបចំនីតិវិធីសវនកម្មដែល សមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ

(គ) វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលបានប្រើនិងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង

(ឃ)សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់របស់អភិបាលលើមូលដ្ឋាននិរន្តភាពនៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនច្បាស់លាស់ជាសារវន្តមានទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ធនាគារក្នុងការបន្តនិរន្តភាពអាជីវកម្ម ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាសលាស់ជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់សវនកររបស់យើង ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុ ឬបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងផ្អែកលើភស្តុតាងសវនកម្ម ដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យធនាគារបញ្ឈប់និរន្តភាពអាជីវកម្ម

(ង) វាយតម្លៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាងថាតើរបាយការណ៍ហិរញ្ញវត្ថុ មានប្រតិបត្តិការនិងព្រឹត្តិការណទាំងនោះបង្ហាញដោយត្រឹមត្រូវឬទេ

យើងបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងៗ វិសាលភាពនិងពេលវេលាដែលបានគ្រោងទុកសម្រាប់ធ្វើសវនកម្ម  និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំនុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលសវនកម្មរបស់យើង។

**តំណាងឱ្យ Kreston Cambodia**

**ប្រតិបត្តិការក្រោមឈ្មោះ ខេម អ៊ីខោនធីង & ថាកសឺវីស**

ស្នងការគណនេយ្យ និងសវនកម្ម

**គាត ហេង CPA, ACCA**

**នាយកសវនកម្ម**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

27 មិថុនា 2023

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | សម្គាល់ | នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022<br>ពាន់រៀល |
|---|---|---|
| **ទ្រព្យសកម្ម** | | |
| សាច់ប្រាក់ក្នុងដៃ | 4 | **31,621** |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារ | 5 | **51,602** |
| ឥណទានផ្តល់ដល់អតិថិជន | 6 | **3,336,494** |
| ទ្រព្យ និងគ្រឿងបរិក្ខារ | 8 | **38,518** |
| ទ្រព្យសកម្មផ្សេងៗ | 7 | **108,939** |
| **សរុបទ្រព្យសកម្ម** | | **3,567,174** |
| **បំណុល** | | |
| បំណុលភាគីសម្ព័ន្ធញាតិ | 20 | **1,845,636** |
| កម្ចី | 10 | **397,442** |
| បំណុលពន្ធលើប្រាក់ចំណូល | 18(a) | **67,633** |
| បំណុលផ្សេងៗ | 9 | **363,223** |
| **សរុបបំណុល** | | **2,673,934** |
| **មូលធន** | | |
| ដើមទុន | 11 | **350,000** |
| ប្រាក់ចំណេញរក្សាទុក | | **543,240** |
| **សរុបមូលធន** | | **893,240** |
| **សរុបបំណុល និង មូលធន** | | **3,567,174** |

កំណត់សម្គាល់ដែលបានភ្ជាប់មកនេះ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ

| | សម្គាល់ | សម្រាប់ការិយបរិច្ឆេទថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022<br>ពាន់រៀល |
|---|---|---|
| ចំណូលការប្រាក់ | 12 | 479,365 |
| ចំណាយការប្រាក់ | 13 | (410,355) |
| **ចំណូលការប្រាក់សុទ្ធ** | | 69,010 |
| | | |
| ចំណូលប្រតិបត្តិការផ្សេងៗ | 14 | 1,787,721 |
| | | |
| ចំណាយបុគ្គលិក | 15 | (818,822) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | 16 | (384,509) |
| សំវិធានធនលើឱនភាពតម្លៃ | 17 | (370,515) |
| **ចំណេញមុនបង់ពន្ធ** | | 282,885 |
| | | |
| ពន្ធលើប្រាក់ចំណូល | 18(b) | (90,916) |
| **ចំណេញក្នុងឆ្នាំ** | | 191,969 |
| | | |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | | - |
| **សរុបប្រាក់ចំណេញពេញលេញក្នុងឆ្នាំ** | | 191,969 |

កំណត់សម្គាល់ដែលបានភ្ជាប់មកនេះ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុនចុះបញ្ជី | ប្រាក់ចំណេញរក្សាទុក | សរុបមូលធន |
|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល |
| សមតុល្យនៅថ្ងៃទី 01 ខែមករា ឆ្នាំ 2022 | 350,000 | 499,488 | 849,488 |
| ចំណេញក្នុងឆ្នាំ | - | 191,969 | 191,969 |
| និយ័តកម្ម | - | (148,217) | (148,217) |
| សមតុល្យនៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2022 | 350,000 | 543,240 | 893,240 |

# របាយការណ៍លំហូរសាច់ប្រាក់

| | សម្គាល់ | សម្រាប់ការិយបរិច្ឆេទថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022<br>ពាន់រៀល |
|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | |
| **ចំណេញមុនបង់ពន្ធ** | | 282,885 |
| **និយ័តកម្មសម្រាប់÷** | | |
| រំលស់ | 8 | 7,458 |
| សំវិធានធនលើឱនភាពតម្លៃ | 17 | 370,515 |
| **ប្រតិបត្តិការខាតមុនបម្រែបម្រួលទុនបង្វិល** | | 660,858 |
| **បម្រែបម្រួល÷** | | |
| ឥណទានផ្តល់ដល់អតិថិជន | 6 | (5,385,823) |
| ទ្រព្យសកម្មផ្សេងៗ | 7 | (83,391) |
| បំណុលផ្សេងៗ | 9 | 96,415 |
| **សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ** | | (4,711,941) |
| បង់ពន្ធលើប្រាក់ចំណូលដែលបានបង់ | 18 | (23,283) |
| **លំហូរសាច់ប្រាក់សុទ្ធដែលប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | (4,735,224) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | |
| ការទិញទ្រព្យ និងគ្រឿងបរិក្ខារ | 8 | (44,214) |
| **លំហូរសាច់ប្រាក់សុទ្ធដែលប្រើក្នុងសកម្មភាពវិនិយោគ** | | (44,214) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ** | | |
| បំណុលភាគីសម្ព័ន្ធញាតិ | 20 | 573,478 |
| កម្ចី | 10 | 48,375 |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញវត្ថុ** | | 621,853 |
| **ការផ្លាស់ប្តូរសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល*** | | (4,157,585) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 01 ខែមករា** | | 290,839 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 31 ខែធ្នូ** | | 83,744 |

*មានប្រតិបត្តិការមិនមែនសាច់ប្រាក់ ការកែតម្រូវត្រូវបានធ្វើឡើងដើម្បីកែតម្រូវប្រាក់ចំណេញរក្សាទុកនូវទឹកប្រាក់ចំនួន 3,950,490 ពាន់រៀល ។

ការផ្ទៀងផ្ទាត់ឡើងវិញនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2022 មានដូចខាងក្រោម÷

| | |
|---|---|
| **សាច់ប្រាក់នៅក្នុងដៃ** | 31,621 |
| **ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារ** | 52,123 |
| | 83,744 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានអំពីក្រុមហ៊ុន និងសកម្មភាពសំខាន់ៗ

ស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម (“MOC”) ក្រោមលេខចុះបញ្ជី No. 2000100564 ចុះថ្ងៃទី 03 ខែ ធ្នូ ឆ្នាំ 2021។ នៅថ្ងៃទី 27 ខែ កញ្ញា ឆ្នាំ 2017 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (“NBC”) ដើម្បីធ្វើប្រតិបត្តិការជាប្រតិបត្តិករឥណទានជនបទក្នុងប្រទេសកម្ពុជា ក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ផ្តោតសំខាន់ក្នុងការធ្វើសកម្មភាពអាជីវកម្មផ្តល់ឥណទានខ្នាតតូច និងការផ្តល់សេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅ#204 ផ្លូវ 19 ភូមិស្ទួនពេជ្រ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ។

## ២. របាយការណ៍អនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs)

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) និងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា (NBC)។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ

### ៣.១ ស្តង់ដារថ្មី វិសោធនកម្ម និងការបកស្រាយ

#### ៣.១.១ ស្តង់ដារថ្មីដែលបានអនុម័ត នាថ្ងៃទី 01 ខែមករា ឆ្នាំ 2022

- វិសោធនកម្មលើ ស រ ហ អ លេខ 3 យោងតាមក្របខ័ណ្ឌទស្សនៈទាន
- វិសោធនកម្មលើ ស គ អ លេខ 16 ស្តីពីទ្រព្យ រោងចក្រ និងគ្រឿងបរិក្ខារ - ដំណើរការមុនពេលប្រើប្រាស់ដោយចេតនា
- វិសោធនកម្មលើ ស គ អ លេខ 37 ស្តីពីកិច្ចសន្យាមិនអាចកែប្រែបាន- ចំណាយនៃការបំពេញកិច្ចសន្យា
- ការកែលម្អប្រចាំឆ្នាំ (វដ្ត 2018-2020):
  - ក្រុមហ៊ុនបុត្រសម្ព័ន្ធជាអ្នកអនុវត្តជាលើកដំបូង (វិសោធនកម្មលើ ស រ ហ អ លេខ 1)
  - ថ្លៃសេវានៅក្នុងការធ្វើតេស្ត “10 ភាគរយ ” សម្រាប់ការមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុ (វិសោធនកម្មលើ ស រ ហអ លេខ 9)
  - ការលើកទឹកចិត្តលើការជួល (វិសោធនកម្មលើ ស រ ហ អ លេខ 16) ការបង់ពន្ធក្នុងរង្វាស់តម្លៃទីផ្សារ (វិសោធនកម្មលើ ស គ អ លេខ 41)

ស្តង់ដារថ្មីមិនត្រូវបានរំពឹងថា នឹងមានផលប៉ះពាល់គួរឱ្យកត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំបច្ចុប្បន្នទេ ដូច្នេះ ស្តង់ដារទាំងនេះ មិនត្រូវបានអនុវត្តដោយក្រុមហ៊ុនទេ។

### ៣.១.២ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយចំពោះស្តង់ដារដែលមានស្រាប់ ដែលចូលជាធរមាន ឬបន្ទាប់ពី ថ្ងៃទី1 ខែមករា ឆ្នាំ 2023

ស្តង់ដារវិសោធនកម្ម និងការបកស្រាយទាំងនោះ ដែលមិនទាន់ចូលជាធរមាននៅឡើយ និងមិនត្រូវបានអនុម័តមុនកាលកំណត់ដោយក្រុមហ៊ុនត្រូវបានបង្ហាញដូចខាងក្រោម÷

- វិសោធនកម្មលើ ស គ អ លេខ 1 ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង
- ស រ ហ អ លេខ 17 ស្តីពីកិច្ចសន្យាធានារ៉ាប់រង
- ស គ អ លេខ 8 និយមន័យនៃការប៉ាន់ប្រមាណគណនេយ្យ
- ស គ អ លេខ 12 ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ

### ៣.១.៣ សុភវិនិច្ឆ័យសំខាន់ៗ និង ការប៉ាន់ស្មានគណនេយ្យ

*ប្រភពសំខាន់ៗនៃកាប៉ាន់ស្មានលើភាពមិនច្បាស់លាស់*

អ្នកគ្រប់គ្រង ជឿជាក់ថាគ្មានការសន្មតសំខាន់ៗណាមួយទាក់ទងនឹងកង្វល់ទៅអនាគត និងប្រភពគន្លឹះផ្សេងទៀតនៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មានក្នុងកាលបរិច្ឆេទនៃការរាយការណ៍ ដែលមានហានិភ័យគួរឱ្យកត់សម្គាល់ក្នុងការបង្កឱ្យមានការកែសម្រួលទៅនឹងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្មក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ក្រៅពីការបង្ហាញខាងក្រោម÷

#### (ក) ឱនភាពនៃឥណទាន និងបុរេប្រទាន

វិធានធនបាត់បង់សម្រាប់ឥណទានផ្តល់ដល់អតិថិជន ត្រូវបានផ្អែកលើការសន្មត់អំពីហានិភ័យនៃការខកខានបង់ និងការព្យាករណ៍អត្រាបាត់បង់ ។ ក្រុមហ៊ុន ប្រើការវិនិច្ឆ័យក្នុងការបង្កើតការសន្មត់ទាំងនេះ និងជ្រើសរើសធាតុចូលដែលសមស្របក្នុងការគណនាឱនភាព ដោយផ្អែកលើទិន្នន័យនៃការទូទាត់កន្លងមក និងលក្ខខណ្ឌទីផ្សារដែលមានស្រាប់ ក៏ដូចជាការប៉ាន់ប្រមាណមើលទៅថ្ងៃអនាគតនៅចុងការិយបរិច្ឆេទបញ្ចប់នៃរបាយការណ៍នីមួយៗ។

#### (ខ) ពន្ធលើប្រាក់ចំណូល

មានប្រតិបត្តិការនិងការគណនាខ្លះ ដែលធ្វើអោយការកំណត់ពន្ធចុងក្រោយអាចខុសគ្នាពីការប៉ាន់ស្មានដំបូង។ ធនាគារទទួលស្គាល់បំណុលពន្ធផ្អែកលើចំណេះដឹងរបស់ខ្លួនអំពីច្បាប់ពន្ធ និងធ្វើការប៉ាន់ស្មានទឹកប្រាក់ពន្ធទៅស្ថានភាពធម្មតារបស់អាជីវកម្មរបស់ខ្លួន។ប្រសិនបើលទ្ធផលចុងក្រោយការប៉ាន់ស្មានខុសគ្នាជាមួយចំនួនពន្ធ ដែលទទួលស្គាល់ពីដំបូងនោះវានឹងមានឥទ្ធិពលលើចំណាយពន្ធ និងពន្ធពន្យារនៅក្នុងកាលរិយបរិច្ឆេទដែលប៉ាន់ស្មាននោះ។

#### (គ) អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មដែលអាចធ្វើការរំលស់

អ្នកគ្រប់គ្រង ត្រូវពិនិត្យឡើងវិញអំពីអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មដែលអាចរំលស់បាននៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗដោយផ្អែកលើការរំពឹងទុកនៃការប្រើប្រាស់ទ្រព្យសកម្មទាំងនោះ។ ភាពមិនប្រាកដប្រជាក្នុងការប៉ាន់ប្រមាណទាំងនេះ ទាក់ទងនឹងភាពយឺតយ៉ាវនៃបច្ចេកវិទ្យាដែលអាចផ្លាស់ប្តូរការប្រើប្រាស់ទ្រព្យ និងគ្រឿងបរិក្ខារ និងកម្មវិធីកុំព្យូទ័រមួយចំនួន។

*ការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យ*

អ្នកគ្រប់គ្រងជឿជាក់ថា មិនមានករណីនៃការអនុវត្តការវិនិច្ឆ័យសំខាន់ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ធនាគារដែលនឹងជះឥទ្ធិពលយ៉ាងសំខាន់ទៅលើចំនួនដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ គោលនយោបាយគណនេយ្យចម្បងដែលត្រូវបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកំណត់ដូចខាងក្រោម។ គោលនយោបាយគណនេយ្យទាំងនេះត្រូវបានអនុវត្តជាប់លាប់ដោយក្រុមហ៊ុនក្នុងអំឡុងឆ្នាំ។

## ៣.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណបរទេស

### ៣.២.១ រូបិយប័ណ្ណមុខងារ និង ការបង្ហាញរូបិយប័ណ្ណ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្ហាញ នៅក្នុងរូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចបឋម ដែលធនាគារមានប្រតិបត្តិការ នោះគឺជារូបិយប័ណ្ណមុខងារ។

រូបិយប័ណ្ណជាតិរបស់កម្ពុជា គឺប្រាក់រៀលខ្មែរ (“រៀលខ្មែរ”)។ អ្នកគ្រប់គ្រង បានកំណត់ប្រាក់រៀលជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់ការវាស់វែង និងបង្ហាញរូបិយប័ណ្ណ ព្រោះវាឆ្លុះបញ្ចាំងពីខ្លឹមសារនៃព្រឹត្តិការណ៍សេដ្ឋកិច្ច និងស្ថានភាពរបស់ក្រុមហ៊ុន។

## ៣.៣ ទ្រព្យ និងគ្រឿងបរិក្ខារ

ទ្រព្យ និងងគ្រឿងបរិក្ខារទាំងអស់ត្រូវបានវាស់ដំបូងដោយតម្លៃដើម។ ថ្លៃដើម រួមមានចំណាយដែលត្រូវបានផ្ទេរដោយផ្ទាល់ទៅនឹងការទិញទ្រព្យសកម្ម និងការចំណាយផ្សេងទៀតដោយផ្ទាល់ដែលនាំឱ្យទ្រព្យសកម្មទៅជាលក្ខខណ្ឌការងារសម្រាប់ការប្រើប្រាស់របស់ខ្លួន។ ដីដែលជាកម្មសិទ្ធ ត្រូវបានរាយការទៅតាមតម្លៃដើមដកនឹងការខាតបង់ឱនភាព ប្រសិនបើមានហើយមិនត្រូវធ្វើរំលស់ទេ។

បន្ទាប់ពីកាទទួលស្គាល់ដំបូង ទ្រព្យ និងគ្រឿងបរិក្ខារទាំងអស់ត្រូវបានរាយការណ៍តាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាព។

**រំលស់**

រំលស់ ត្រូវបានគណនាដោយប្រើវិធីសាស្ត្ររំលស់ថេរតាមអត្រាប្រចាំឆ្នាំដូចខាងក្រោម÷

| | |
|---|---|
| ការជួសជុលការិយាល័យ | 20% |
| គ្រឿងសង្ហារិម | 25%-50% |
| ឧបករណ៍កំព្យូទ័រ | 33%-50% |
| ឧបករណ៍បរិក្ខា | 33% |

តម្លៃកាកសំណល់ អាយុកាលនៃការប្រើប្រាស់ និងវិធីសាស្ត្រធ្វើរំលស់ ត្រូវបានពិនិត្យឡើងវិញនៅចុងបញ្ចប់នៃរយៈពេលរបាយការណ៍នីមួយៗដើម្បីធានាថាវិធីសាស្ត្រ នៃការធ្វើរំលស់និងរយៈពេលនៃការរំលស់គឺស្របទៅនឹងការប៉ាន់ស្មានទុកជាមុន និងការរំពឹងទុកនៃការប្រើប្រាស់សម្រាប់ផលចំណេញសេដ្ឋកិច្ចនាពេលអនាគត ។

ទ្រព្យ និងគ្រឿងបរិក្ខារ ត្រូវបានមិនទទួលស្គាល់នៅពេលលក់ចេញ ឬនៅពេលដែលគ្មានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតត្រូវបានរំពឹងទុកពីការប្រើប្រាស់ ឬការលក់ចេញរបស់វា។ ប្រាក់ចំណេញ ឬខាត ណាមួយដែលកើតចេញពីការមិនទទួលស្គាល់ទ្រព្យ ត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍នៃប្រាក់ចំណូលសរុបក្នុងឆ្នាំដែលទ្រព្យត្រូវបានលក់ចេញ។

### ឱនភាពនៃតម្លៃលើទ្រព្យ និងគ្រឿងបរិក្ខារ

សម្រាប់គោលបំណងក្នុងការវាយតម្លៃលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានចាត់ថ្នាក់ជាក្រុមតូចៗ ទៅតាមលំហូរសាច់ប្រាក់ដាច់ដោយឡែករបស់ទ្រព្យសកម្មទាំងនោះ (ឯកតាបង្កើតសាច់ប្រាក់) ។ ជាលទ្ធផល ទ្រព្យសកម្មមួយចំនួនត្រូវបានវាយតម្លៃរកឱនភាពដាច់ដោយឡែក ហើយមួយចំនួនទៀត ត្រូវបានវាយតម្លៃជាក្រុមទៅតាមឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងសមតុល្យ តាមតម្លៃដែលទ្រព្យសកម្ម ឬសមតុល្យយោងរបស់ឯកតាបង្កើតសាច់ប្រាក់លើសពីសមតុល្យដែលអាចប្រមូលមកវិញបាន លើតម្លៃណាមួយដែលខ្ពស់ជាងនៃតម្លៃសមស្របដកថ្លៃដើមក្នុងការលក់ និងតម្លៃប្រើប្រាស់។ ដើម្បីកំណត់តម្លៃប្រើប្រាស់ គណៈគ្រប់គ្រងធ្វើការប៉ាន់ស្មានលើលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកពីឯកតាបង្កើតសាច់ប្រាក់នីមួយៗ និងកំណត់អត្រាការប្រាក់ដ៏សមរម្យ ដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យដែលប្រើប្រាស់ក្នុងការធ្វើតេស្តឱនភាពនៃតម្លៃ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន ហើយត្រូវបានធ្វើនិយ័តកម្មក្នុងករណីដែលចាំបាច់ដើម្បីបញ្ចៀសផលប៉ះពាល់លើការរៀបចំឡើងវិញ និងការរៀបចំបន្ថែមទៅលើទ្រព្យសកម្មនាពេលអនាគត។ ការធ្វើអប្បហារត្រូវបានកំណត់ជាលក្ខណៈដាច់ដោយឡែកសម្រាប់ឯកតាបង្កើតសាច់ប្រាក់នីមួយៗ និងឆ្លុះបញ្ចាំងពីទម្រង់ហានិភ័យនីមួយៗ ដូចដែលបានវាយតម្លៃដោយគណៈគ្រប់គ្រង។

រាល់ទ្រព្យសកម្មត្រូវបានវាយតម្លៃជាថ្មីទៀតទាត់ ដើម្បីត្រួតពិនិត្យថា ការខាតបង់ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មដែលបានទទួលស្គាល់ពីមុន នៅតែបន្តកើតមានឬទេ។ កំណត់ត្រាលើឱនភាពនៃតម្លៃពីមុនអាចនឹងត្រូវបានកែសម្រួលឡើងវិញប្រសិនបើឯកតាបង្កើតសាច់ប្រាក់ដែលអាចប្រមូលបានលើសពីសមតុល្យយោងរបស់វា។

## ៣.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់នៅក្នុងដៃ និងប្រាក់បញ្ញើជាមួយធនាគារផ្សេងៗ ដែលអាចបំលែងជាសាច់ប្រាក់ជាក់លាក់ និងប្រឈមនឹងហានិភ័យនៃការផ្លាស់ប្តូរតម្លៃតិចៗ។

## ៣.៥ ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជារួមបញ្ចូលទាំងប្រាក់តម្កល់តាមបទប្បញ្ញត្តិ ត្រូវបានកំណត់តាមថ្លៃដើម។ ប្រាក់តម្កល់តាមបទប្បញ្ញត្តិ ត្រូវបានរក្សាទុកជាមួយធនាគារជាតិនៃកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីក្រុមហ៊ុននិងគ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមាដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ហើយប្រាក់តម្កល់ទាំងនេះ មិនមែនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ក្រុមហ៊ុនឡើយ។ ដូច្នេះហើយ ប្រាក់តម្កល់តាមបទប្បញ្ញត្តិ មិនត្រូវបានចាត់ទុកជាផ្នែកនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលឡើយក្នុងគោលបំណងរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

## ៣.៦ ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ ត្រូវបានកំណត់តាមថ្លៃដើម។ ក្រុមហ៊ុន ធ្វើសំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃសម្រាប់គណនីប្រាក់តម្កល់ជាមួយធនាគារក្នុងអត្រា 1% ដោយអនុលោមតាមប្រកាសលេខ ធ7-017-344 ចុះថ្ងៃទី 1 ខែ ធ្នូ ឆ្នាំ 2017 និងសារាចរលេខ ធ7-018-001 ចុះថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2018 ស្តីពីការធ្វើចំណាត់ថ្នាក់ហានិភ័យឥណទាននិងការធ្វើសំវិធានធនឱនភាពនៃតម្លៃសម្រាប់ក្រុមហ៊ុននិងគ្រឹះស្ថានហិរញ្ញវត្ថុ។

## ៣.៧ ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្រប បូកបញ្ចូលជាមួយចំណាយផ្សេងៗ ទាក់ទិនផ្ទាល់នឹងប្រតិបត្តិការកម្ចី ហើយត្រូវបានវាស់វែងជាបន្តបន្ទាប់តាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ ក្នុងនោះផងដែរ ឥណទានផ្តល់ដល់អតិថិជន ត្រូវបានរាប់បញ្ចូលទាំងប្រាក់ដើមបូកជាមួយការប្រាក់បង្គរ ដកសំវិធានធនលើឱនភាពតម្លៃឥណទាន។

ឥណទានដែលត្រូវលុបចោលពីគណនីចំណេញ ឬខាត ត្រូវបានធ្វើសំវិធានធនទាំងស្រុង ហើយសមតុល្យដែលមិនទាន់បានទូទាត់នាកាលបរិច្ឆេទកំណត់ ឬនៅពេលដែលមានការបញ្ជាក់ច្បាស់លាស់ថាសមតុល្យទាំងនោះ មិនអាចប្រមូលមកវិញបាន។ ឥណទានដែលបានលុបចេញ ត្រូវបានដកចេញពីផលប័ត្រឥណទានជំពាក់ និងដកចេញពីសមតុល្យ សំវិធានធនលើឱនភាពតម្លៃឥណទាន។

លទ្ធភាពដែលអាចប្រមូលមកវិញបាននៃឥណទានដែលបានលុបចោលកាលពីមុន ត្រូវបានទទួលស្គាល់ជាចំណូលប្រតិបត្តិការផ្សេងៗ នៅក្នុងគណនីចំណេញ ឬខាត។

## ៣.៨ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមថ្លៃដើម។ ការប៉ាន់ស្មាន ដែលបានធ្វើឡើង សម្រាប់គណនីត្រូវទទួលដែលសង្ស័យ ដោយផ្អែកលើការត្រួតពិនិត្យឡើងវិញលើសមតុល្យដែលនៅជំពាក់នាកាលបរិច្ឆេទនៃរបាយការណ៍។

## ៣.៩ ឱនភាពនៃតម្លៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

សម្រាប់គោលបំណងក្នុងការវាយតម្លៃលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានចាត់ថ្នាក់ជាក្រុមតូចៗ ទៅតាមលំហូរសាច់ប្រាក់ដាច់ដោយឡែករបស់ទ្រព្យសកម្មទាំងនោះ (ឯកតាបង្កើតសាច់ប្រាក់) ។ ជាលទ្ធផល ទ្រព្យសកម្មមួយចំនួនត្រូវបានវាយតម្លៃរកឱនភាពដាច់ដោយឡែក ហើយមួយចំនួនទៀត ត្រូវបានវាយតម្លៃជាក្រុមទៅតាមឯកតាបង្កើតសាច់ប្រាក់។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងសមតុល្យ តាមតម្លៃដែលទ្រព្យសកម្ម ឬសមតុល្យយោងរបស់ឯកតាបង្កើតសាច់ប្រាក់លើសពីសមតុល្យដែលអាចប្រមូលមកវិញបាន លើតម្លៃណាមួយដែលខ្ពស់ជាងនៃតម្លៃសមស្របដកថ្លៃដើមក្នុងការលក់ និងតម្លៃប្រើប្រាស់។ ដើម្បីកំណត់តម្លៃប្រើប្រាស់ គណៈគ្រប់គ្រងធ្វើការប៉ាន់ស្មានលើលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកពីឯកតាបង្កើតសាច់ប្រាក់នីមួយៗ និងកំណត់អត្រាការប្រាក់ដ៏សមរម្យ ដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យដែលប្រើប្រាស់ក្នុងការធ្វើតេស្តឱនភាពនៃតម្លៃ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុន ហើយត្រូវបានធ្វើនិយ័តកម្មក្នុងករណីដែលចាំបាច់ដើម្បីបញ្ចៀសផលប៉ះពាល់លើការរៀបចំឡើងវិញ និងការរៀបចំបន្ថែមទៅលើទ្រព្យសកម្មនាពេលអនាគត។ ការធ្វើអប្បហារ

ត្រូវបានកំណត់ជាលក្ខណៈដាច់ដោយឡែកសម្រាប់ឯកតាបង្កើតសាច់ប្រាក់នីមួយៗ និងឆ្លុះបញ្ចាំងពីទម្រង់ហានិភ័យនីមួយៗ ដូចដែលបានវាយតម្លៃដោយគណៈគ្រប់គ្រង។

ទ្រព្យសកម្មដែលត្រូវរំលស់លើទ្រព្យសកម្មរូបិយ ឬរំលស់លើទ្រព្យសកម្មអរូបិយ ត្រូវបានវាយតម្លៃនារាល់ការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានការចង្អុលបង្ហាញថាទ្រព្យសកម្មមានឱនភាពនៃតម្លៃឬទេ។ ក្នុងករណីដែលមានការបង្ហាញថាមានទ្រព្យសកម្មអាចកើតមាននូវឱនភាពនៃតម្លៃ នោះសមតុល្យយោងរបស់ទ្រព្យសកម្ម (ឬឯកតាបង្កើតសាច់ប្រាក់) ទៅលើទ្រព្យសកម្មដែលត្រូវបានគេបែងចែក គឺត្រូវបានគេធ្វើតេស្តលើឱនភាពនៃតម្លៃ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងសមតុល្យដែលសមតុល្យយោងរបស់ទ្រព្យសកម្ម លើសពីសមតុល្យដែលអាចប្រមូលមកវិញបានរបស់វា។

សមតុល្យដែលប្រមូលមកវិញបាន គឺខ្ពស់ជាងតម្លៃសមតុល្យរបស់ទ្រព្យសកម្ម (ឬឯកតាបង្កើតសាច់ប្រាក់) ដកថ្លៃដើមក្នុងការលក់ និងតម្លៃប្រើប្រាស់របស់វា។ ក្នុងគោលបំណងវាយតម្លៃលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានចាត់ជាក្រុមក្នុងកម្រិតទាបបំផុតដែលមានលំហូរសាច់ប្រាក់ដែលអាចកំណត់អត្តសញ្ញាណបានដាច់ដោយឡែកពីគ្នា (ឯកតាបង្កើតសាច់ប្រាក់)។

ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ក្រៅពីមូលនិធិពាណិជ្ជកម្មដែលកើតមានឱនភាពនៃតម្លៃ ត្រូវបានត្រួតពិនិត្យឡើងវិញ សម្រាប់ការកត់ត្រាបញ្ច្រាស់លើឱនភាពនៃតម្លៃដែលអាចកើតមាននាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

រាល់ទ្រព្យសកម្មត្រូវបានវាយតម្លៃជាទៀតទាត់ ដើម្បីត្រួតពិនិត្យថា ការខាតបង់ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មដែលបានទទួលស្គាល់ពីមុន នៅតែបន្តកើតមានឬទេ។ កំណត់ត្រាលើឱនភាពនៃតម្លៃពីមុនអាចនឹងត្រូវបានកែសម្រួលឡើងវិញប្រសិនបើឯកតាបង្កើតសាច់ប្រាក់ដែលអាចប្រមូលបានលើសពីសមតុល្យយោងរបស់វា។

## ៣.១០ កម្ចី និងបំណុលផ្សេងៗ

កម្ចី និងបំណុលផ្សេងៗ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃប្រតិបត្តិការ (រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ) និងត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

## ៣.១១ មូលធនបម្រុង និងប្រាក់ចំណេញរក្សាទុក

ដើមទុន តំណាងឱ្យតម្លៃចារឹករបស់ក្រុមហ៊ុនដែលបានចេញផ្សាយ។ ប្រាក់ចំណេញរក្សាទុក រួមមានចំណេញនាពេលបច្ចុប្បន្ន និងចំណេញពីឆ្នាំមុនទាំងអស់។

## ៣.១២ សំវិធានធនតាមបទប្បញ្ញត្តិ

ការចាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធន ដល់គ្រឹះស្ថានហិរញ្ញវត្ថុដោយអនុលោមតាមប្រកាសលេខ ធ7-017-344 ចុះថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2017 ដែលចេញដោយធនាគារជាតិនៃកម្ពុជា ផ្តល់ការណែនាំអំពីការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធនតាមបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា ដែលបានសង្ខេបដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកំណត់ | អត្រាសំវិធានធន |
|---|---|---|
| **កម្ចីរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ)** | | |
| ឥណទានធម្មតា/ ស្តង់ដារ | 0 - 14 ថ្ងៃ | 1 % |
| ឥណទានឃ្លាំមើល | 15 ថ្ងៃ- 30 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | 31 ថ្ងៃ -60 ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 61 ថ្ងៃ - 90 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ច្រើនជាង 91 ថ្ងៃ | 100% |

| ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ) | ចំនួនថ្ងៃហួសកំណត់ | អត្រា សំវិធានធន |
|---|---|---|
| ឥណទានធម្មតា/ ស្តង់ដារ | 0-29 ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | 30 ថ្ងៃ- 89 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | 90 ថ្ងៃ- 179 ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 180 ថ្ងៃ- 359 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ច្រើនជាង 360 ថ្ងៃ | 100% |

មាត្រា 73 នៃប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់ហានិភ័យ និងឱនភាពហានិភ័យឥណទានតម្រូវឱ្យ ក្រុមហ៊ុនធ្វើការប្រៀបធៀបសំវិធានធនដែលបានគណនា ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ហើយស្របតាមប្រកាសលេខ ធ7-017-344 ដែលមានចែងដូចខាងក្រោម÷

1. ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ត្រូវបានគណនាដោយអនុលោមតាមសេចក្តីប្រកាស គឺទាបជាងសំវិធានធនដែលត្រូវបានគណនាដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសខ្នាតតូច និងមធ្យម (“CIFRS for SMEs”) ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន ដែលត្រូវបានគណនានោះដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។
